**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខៈ ០៧៣/១៥ គជបជ

# សេចក្ដីសម្រេច
# ស្ដីពី
# ការតែងតាំងសមាសភាពក្រុមការងារការពារជនរងគ្រោះ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការ បង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្ដីសម្រេចរាជរដ្ឋាភិបាល លេខ ១៤៥ សសរ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ស្ដីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្ដីសម្រេចលេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

**ប្រការ១.**

ត្រូវបានតែងតាំងសមាសភាព ក្រុមការងារការពារជនរងគ្រោះនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្ដម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) **ប្រធាន**

| | | | |
|---|---|---|---|
| ២. លោកជំទាវ | **ខៀវ មូរី** | រដ្ឋលេខាធិការក្រសួង ស.អ.យ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្តម | **អ៊ិន វិធុរះ** | អនុរដ្ឋលេខាធិការក្រសួង ស.អ.យ | អនុប្រធាន |
| ៤. លោកជំទាវ | **ម៉ែន វិភស៊ី** | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | អនុប្រធាន |
| ៥. ល.ជ.ឧត្តមសេនីយ៍ទោ | **ប៉ុណ្ណ សំខាន់** | អគ្គលេខាធិការរង គ.ជ.ប.ជ | អនុប្រធាន |
| ៦. ឯកឧត្តម | **តូច ចាន់នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងស.អ.យ | សមាជិក |
| ៧. ល.ជ.ឧត្តមសេនីយ៍ឯក | **ឌុច ដាណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ៨. លោក | **សុច សុផាន់ណារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ | សមាជិក |
| ៩. លោកឧត្តមសេនីយ៍ត្រី | **ខ៉ែត សំណាង** | នាយករងទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ | សមាជិក |
| ១០.លោកស្រី | **អ៊ីង វណ្ណឫទ្ធី** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ក្រសួង ស.អ.យ | សមាជិក |
| ១១. លោក | **ស៊ិន សេងហុក** | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ១២. លោក | **ខេង ហៀង** | ប្រធាននាយកដ្ឋានការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣. លោក | **ជីន ចន** | អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់ ក្រសួងកិច្ចការនារី | សមាជិក |
| ១៤. លោក | **គឹម សុវណ្ណា** | អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥. លោកស្រី | **ខាន់ ច័ន្ទវណ្ណា** | អនុប្រធាននាយកដ្ឋាន ក្រសួងព័ត៌មាន | សមាជិក |
| ១៦.ល.ស.ឧត្តមសេនីយ៍ត្រី | **ណា នាង** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៧.លោកឧត្តមសេនីយ៍ត្រី | **ម៉ុក ប៊ុនឈាង** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៨. លោកស្រី | **កែវ ម៉ាលី** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិង សមាហរណកម្មជនរងគ្រោះ ក្រសួង ស.អ.យ | សមាជិក |
| ១៩. លោកវរសេនីយ៍ទោ | **សោម វណ្ណេត** | នាយរងការិយាល័យស្រាវជ្រាវ នាយកដ្ឋានប្រឆាំងការជួញដូរ មនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ | សមាជិក |
| ២០. លោកវរ.ទោ | **ស សាវុធ** | នាយរងការិយាល័យបទល្មើសជួញដូរមនុស្ស ស្នងការដ្ឋានយុត្តិធម៌ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២១. លោក | **ឈុប ឫទ្ធា** | ប្រធានផ្នែកការពារកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិក |
| ២២. ឯកឧត្តម | **នុត សវនា** | សមាជិកគណៈកម្មាធិការកណ្តាលសហភាពសហព័ន្ធយុវជន | សមាជិក |
| ២៣. លោក | **ម៉ម ដារ៉ូ** | អនុប្រធានការិយាល័យស្តារនិងទំនាក់ទំនងគ្រួសារនៃ នាយកដ្ឋានទំនាក់ទំនង កាកបាទក្រហមកម្ពុជា | សមាជិក |

| | | | |
|---|---|---|---|
| ២៤. តំណាង | | អង្គការសកម្មភាពសហប្រជាជាតិដើម្បីប្រឆាំងការជួញដូរមនុស្ស | សមាជិក |
| ២៥. លោក | **នុត សំអុល** | ជំនួយការកម្មវិធីអង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) | សមាជិក |
| ២៦. កញ្ញា | **ឃឹម សុភារី** | ជំនួយគម្រោង UNODC | សមាជិក |
| ២៧. លោក | **ឃ្លាំង រឹម** | មន្ត្រីគម្រោងអង្គការពលកម្មអន្តរជាតិ (ILO) | សមាជិក |
| ២៨. លោក | **ហេង សុហ៊ាញ** | នាយកកម្មវិធីបញ្ឈប់ការជួញដូរមនុស្ស អ.កទស្សនៈពិភពលោក | សមាជិក |
| ២៩. លោក | **ថា សារ៉ាខុច** | មន្ត្រីជំនាញផ្នែកនគរបាលការពារជនរងគ្រោះនៃគម្រោងប្រឆាំងការជួញដូរមនុស្ស អង្គការវីនរ៉ក់ | សមាជិក |
| ៣០. លោកស្រី | **ម៉ុក បញ្ញាវិចិត្រ** | ប្រធានអង្គការ ជួយស្ត្រីមានវិបត្តិ (CWCC) | សមាជិក |
| ៣១. លោក | **ស៊ុន ទ៉ារិទ្ធ** | ប្រធាន អង្គការសម្ព័ន្ធចាប់ដៃ | សមាជិក |
| ៣២. លោក | **សេក សុផល** | ប្រធានកម្មវិធីមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ | សមាជិក |
| ៣៣.លោក | **ឆន អាន** | ប្រធានកម្មវិធីសុខភាព សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ | សមាជិក |

**ប្រការ២.**

ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារការពារជនរងគ្រោះ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ៤ នៃសេចក្តីសម្រេចគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពី ការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព ។ ប្រធានក្រុមការងារ អាចចាត់តាំងមន្ត្រី ជាជំនួយតាមការចាំបាច់ ។

អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិដែលមានគោលដៅស្របទៅនឹងភារកិច្ចដែលកំណត់ដោយសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ខាងលើនេះ អាចស្នើសុំចូលជាសមាជិកក្រុមការងារ មកប្រធានក្រុមការងារការពារជនរងគ្រោះ និងចាត់តំណាងផ្លូវការមកចូលរួម តាមការអញ្ជើញរបស់ប្រធានក្រុម ។

**ប្រការ៣.**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិ និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អគ្គលេខាធិការ គ.ជ.ប.ជ
- ក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ
- ក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ
- សាមីខ្លួនដូចប្រការ១
- ឯកសារ កាលប្បវត្តិ